APHR ASEAN PARLIAMENTARIANS FOR HUMAN RIGHTS

# របាយការណ៍ថ្មីបង្ហាញពីស្ថានភាពកាន់តែអាក្រក់និងប្រកបដោយហានិភ័យខ្ពស់ចំពោះសមាជិកសភានៅអាស៊ីអាគ្នេយ៍

ហ្សាកាតា៖ សមាជិកសភានៅអាស៊ីអាគ្នេយ៍នៅតែប្រឈមមុខនឹងហានិភ័យនៃការសងសឹកដោយគ្រាន់តែអនុវត្តក្នុងអាណត្តិរបស់ខ្លួន ឬបញ្ចេញមតិនយោបាយរបស់ពួកគេ នេះបើយោងតាមរបាយការណ៍ប្រចាំឆ្នាំចុងក្រោយស្តីពីសមាជិកសភាដែលប្រឈមហានិភ័យក្នុងចំណោមសមាជិកសភាអាស៊ានដើម្បីសិទ្ធិមនុស្ស (APHR) ដែលបានបញ្ចេញឲ្យដឹងនៅថ្ងៃនេះក្នុងទីក្រុងហ្សាកាតា។

“ហានិភ័យកើនឡើងទាំងលើរូបរាងកាយ និងដ៏ទៃផ្សេងទៀត ដែលសមាជិកសភាក្នុងតំបន់កំពុងប្រឈម គឺមិនអាចទទួលយកបានទាល់តែសោះ និងជាបញ្ហានៃការព្រួយបារម្ភបំផុត។ អ្នកតំណាងរាស្ត្រគឺជាតំណាងរបស់ប្រជាពលរដ្ឋ ដូច្នេះសុវត្ថិភាព និងសេរីភាពរបស់ពួកគាត់គឺឆ្លុះបញ្ចាំងពីដំណើរការល្អរឺមិនល្អនៃលទ្ធិប្រជាធិបតេយ្យនៅកន្លែងដែលពួកគាត់ធ្វើការ។ យើងអំពាវនាវឱ្យអាស៊ាន ក៏ដូចជារដ្ឋសមាជិកអាស៊ាន អនុវត្តការការពារឱ្យបានគ្រប់គ្រាន់ដល់ពួកគាត់ និងដាក់សម្ពាធលើរដ្ឋាភិបាលទាំងនោះដែលបានធ្វើទុក្ខបុកម្នេញសមាជិកសភារបស់ពួកគេដោយអយុត្តិធម៌”។

APHR ASEAN PARLIAMENTARIANS FOR HUMAN RIGHTS

ឆ្នាំ ២០២២
យើងបានឃើញនិន្នាការកាន់តែអាក្រក់ទៅៗសម្រាប់សមាជិក
សភាដែលប្រឈមនឹងហានិភ័យនៅក្នុងតំបន់
ជាពិសេសនៅក្នុងប្រទេសមីយ៉ាន់ម៉ា
ដែលសមាជិកសភាប្រឈមនឹងគ្រោះថ្នាក់កាន់តែខ្លាំងឡើងប
ន្ទាប់ពីរដ្ឋប្រហារថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០២១។
សមាជិកសភាម្នាក់គឺលោក Kyaw Myo Min
ត្រូវបានគេធ្វើទារុណកម្មរហូតដល់ស្លាប់នៅក្នុងការឃុំឃាំង
ហើយអតីតសមាជិកសភាម្នាក់គឺលោក Phyo Zeya Thaw
ត្រូវបានប្រហារជីវិតរួមជាមួយអ្នកទោសនយោបាយបីនាក់ទៀ
តនៅក្នុងប្រទេសមីយ៉ាន់ម៉ា។
ចំនួនអ្នកតំណាងរាស្ត្រដែលត្រូវបានឃុំខ្លួននៅទូទាំងអាស៊ីអា
គ្នេយ៍នៅតែមានកម្រិតខ្ពស់ដែលមានចំនួន ៨៥ នាក់
ដោយមាន ៨៤ នាក់នៅក្នុងប្រទេសមីយ៉ាន់ម៉ា
និងអតីតសមាជិកព្រឹទ្ធសភា Leila de Lima
នៅក្នុងប្រទេសហ្វីលីពីន។

លោក Charles Santiago អតីតសមាជិកសភាម៉ាឡេស៊ី
និងជាសហប្រធាន APHR បានលើកឡើងថា

APHR ASEAN PARLIAMENTARIANS FOR HUMAN RIGHTS

“សូម្បីតែសមាជិកសភាមីយ៉ាន់ម៉ា
ដែលបានសម្រេចរត់ទៅជ្រកកោននៅប្រទេសជិតខាង

ដូចជាប្រទេសថៃ នៅតែស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់។
ពួកគាត់រាប់សិបនាក់កំពុងរស់នៅក្នុងទីប្រជុំជនតាមបណ្តោយ
ព្រំដែនថៃ មីយ៉ាន់ម៉ា
ហើយពួកគាត់មានអារម្មណ៍ថាពួកគេរងការយាយីដោយប៉ូលី
សជាញឹកញាប់ដោយសារជាជនចំណាកស្រុកដែលគ្មានឯក
សារ ដោយតែងតែភ័យខ្លាចជាប់ឃុំ
ឬអាក្រក់ជាងនេះទៅទៀត
នឹងត្រូវចាប់បញ្ជូនទៅកាន់ប្រទេសរបស់ពួកគាត់
ដែលពួកគាត់នឹងត្រូវប្រឈមមុខនឹងការចាប់ខ្លួន
និងទំនងជាទទួលការធ្វើទារុណកម្ម
ឬអាក្រក់ជាងនេះទៅទៀត គឺធ្លាក់ក្នុងដៃរបស់របបយោធា”

នៅខាងក្រៅប្រទេសមីយ៉ាន់ម៉ា
ជាពិសេសនៅក្នុងប្រទេសកម្ពុជា ម៉ាឡេស៊ី ហ្វីលីពីន
និងប្រទេសថៃ
ករណីនៃការវាយប្រហារលើរាងកាយកម្រកើតមាន
ប៉ុន្តែរដ្ឋាភិបាលតែងតែប្រើការចោទប្រកាន់ដោយហេតុផលន
យោបាយប្រឆាំងនឹងសមាជិកសភាបក្សប្រឆាំង។
ការសងសឹក
និងការគំរាមកំហែងមិនត្រឹមតែដោយប្រព័ន្ធតុលាការប៉ុណ្ណោះ
ទេ
តែសមាជិកសភាក៏ប្រឈមមុខនឹងការយាយីតាមអ៊ីនធឺណិត
និងក្លាយជាជនរងគ្រោះនៃយុទ្ធនាការផ្សព្វផ្សាយព័ត៌មានមិនពិ
ត ក៏ដូចជាពាក្យសំដីស្អប់ខ្ពើមផងដែរ។

APHR ASEAN PARLIAMENTARIANS FOR HUMAN RIGHTS

នៅកម្ពុជា រដ្ឋាភិបាលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបើកសវនាការកាត់ទោសទ្រង់ទ្រាយធំជាបន្តបន្ទាប់ និងកាត់ទោសសមាជិក និងអ្នកគាំទ្រគណបក្សសង្គ្រោះជាតិជាង ១០០នាក់ រួមទាំងអតីតសមាជិកសភាមួយចំនួនកំបាំងមុខផងដែរ។ ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ និងការបំភិតបំភ័យពីសំណាក់រដ្ឋាភិបាលទៅលើសមាជិក និងអ្នកគាំទ្រគណបក្សប្រឆាំង អ្នកការពារសិទ្ធិមនុស្ស សកម្មជនការពារសិទ្ធិដីធ្លី និងបរិស្ថាន និងអ្នកសារព័ត៌មាន ត្រូវបានគេរំពឹងថានឹងបន្តកើនឡើងរហូតដល់ការបោះឆ្នោតសកលខាងមុខ ដែលគ្រោងនឹងធ្វើឡើងនៅខែកក្កដា ២០២៣។

លោក Kasit Piromya អតីតរដ្ឋមន្ត្រីការបរទេសថៃ និងជាសមាជិកក្រុមប្រឹក្សាភិបាល APHR បានលើកឡើងថា

"លោក ហ៊ុន សែន និងគណបក្សរបស់លោកបានបង្កើតរបបផ្តាច់ការឯកបក្សជាបណ្តើរៗក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ។ ដំណើរការនេះមានភាពយឺតៗ ដែលធ្វើឲ្យមនុស្សមួយចំនួនតូចអាចកត់សម្គាល់ឃើញ ប៉ុន្តែសញ្ញាទាំងឡាយបានបង្ហាញយ៉ាងច្បាស់លាស់ដោយមិនស្រពិចស្រពិល ហើយជាលទ្ធផលនាំឱ្យមានរដ្ឋផ្តាច់ការស្ទើរតែទាំងស្រុង។ សហគមន៍អន្តរ

ASEAN PARLIAMENTARIANS FOR HUMAN RIGHTS

APHR

ASEAN PARLIAMENTARIANS FOR HUMAN RIGHTS

APHR

ជាតិត្រូវតែឲ្យរដ្ឋាភិបាលលោក ហ៊ុន សែន ទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សដ៏រីករាលដាលរបស់ខ្លួន និងធានាឱ្យគណបក្សប្រឆាំង និងបេក្ខជនរបស់ពួកគេអាចប្រកួតប្រជែងក្នុងការបោះឆ្នោតសកលឆ្នាំ ២០២៣ ក្នុងបរិយាកាសសេរី និងយុត្តិធម៌ ជាមួយទីលានដែលមានស្តង់ដាខ្ពស់មួយ មុនពេលវាយឺតពេល។”

ទន្ទឹមនឹងនេះ នៅក្នុងប្រទេសម៉ាឡេស៊ី និងហ្វីលីពីន ការផ្សព្វផ្សាយព័ត៌មានមិនពិតតាមអ៊ីនធឺណិត និងការប្រើប្រាស់ពាក្យស្អប់ខ្ពើមប្រឆាំងនឹងសមាជិកសភានៅតែបន្តរីករាលដាល។ សមាជិកសភាបក្សប្រឆាំងទាំងក្នុងប្រទេសហ្វីលីពីន និងថៃក៏ជារឿយៗប្រឈមមុខនឹងការយាយីតាមប្រព័ន្ធតុលាការ តាមរយៈការប្រើប្រាស់ច្បាប់ដែលទូលំទូលាយពេក ខណៈដែលការបន្តកើតមាននៃច្បាប់ដ៏តឹងរ៉ឹង ដូចជាច្បាប់បះបោរ និងច្បាប់ទំនាក់ទំនង និងពហុព័ត៌មានក្នុងប្រទេសម៉ាឡេស៊ី នៅតែជាការគំរាមកំហែងដែលព្យួរលើក្បាលរបស់អ្នករិះគន់រដ្ឋាភិបាលដែលមានសក្តានុពល។

“ការប្រើប្រាស់ច្បាប់ជាអាវុធប្រឆាំងនឹងអ្នកនយោបាយគឺគ្មានអ្វីក្រៅពីការបំផ្លិចបំផ្លាញនីតិរដ្ឋ

ដែលជាមូលដ្ឋានគ្រឹះមួយនៃលទ្ធិប្រជាធិបតេយ្យ។
នៅក្នុងប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍ ច្បាប់
និងតុលាការត្រូវបានប្រើប្រាស់ជាឧបករណ៍របស់អ្នកកាន់អំ
ណាច ជាជាងអ្វីដែលពួកគេគួរតែជា៖ ឧបករណ៍ដើម្បីការពារ
ឬបញ្ឈប់ការបំពាន។
ចាំបាច់ត្រូវឲ្យរដ្ឋាភិបាលដែលរំលោភអំណាចរបស់ខ្លួនទទួល
ខុសត្រូវ
ហើយធ្វើឲ្យពួកគេយល់ថាពួកគេមិនអាចនៅពីលើច្បាប់បាន
ទេ”។ នេះបើតាមលោកស្រី មូរ សុខហួរ
អតីតសមាជិកសភាមកពីកម្ពុជា
និងជាសមាជិកក្រុមប្រឹក្សាភិបាល APHR បានគូសបញ្ជាក់